01070156

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26/02/2015
ម៉ោង (Time/Heure): 15:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/263

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

### សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

### ថ្ងៃ ចន្ទ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

## សវនាការលើកស្តុតាង - ថ្ងៃ ២៤៤

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង Matteo CRIPPA

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ គុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ាង, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក ស្រ៊ា រតនៈ, លោក Vincent de Wilde d'Estmael |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី ទី ស្រីនណា |

SC

| | |
|---|---|
| សាក្សី/ដើមបណ្ដឹង/អ្នកជំនាញ ៖ ឯម កឿង (2-TCW-954), ភ្លៅ យ៉ាវ (2-TCW-934) | |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធារី | |
| ផ្សេងៗ៖ កញ្ញា ស្រី ណាក់, លោក ហ៊ូ ជីសេង, លោក Mario D'ALESSANDRO, កញ្ញា ណី សុមេត្តា | |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩. ០៨ | បញ្ចប់ម៉ោង៖ ១៦.០១ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៨ | បញ្ចប់ម៉ោង៖ ១០.៣៦ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣២ | បញ្ចប់ម៉ោង៖ ១៣.២២ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៣ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២៧ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៨ | ០៩.១១ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ | អង្គជំនុំជម្រះ | ០៩.១១ | ០៩.១៤ |
| ការកត់សម្គាល់លើការដាក់បន្ថែមនូវកំណត់ហេតុស្ដាប់ចម្លើយពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២ | មេធាវីការពារក្ដី នួន ជា | ០៩.១៤<br>១៥.២៥ | ០៩.១៩<br>១៥.៣០ |
| | មេធាវីការពារក្ដី ខៀវ សំផន | ០៩.១៩<br>១៥.៣០ | ០៩.២១<br>១៥.៣៤ |
| | សហព្រះរាជអាជ្ញា | ០៩.២១<br>១៥.៣៦ | ០៩.២៣<br>១៥.៤៤ |
| | មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី | ០៩.២៣<br>១៥.៤៤ | ០៩.២៤<br>១៥.៤៦ |
| | អង្គជំនុំជម្រះ | ០៩.៣០<br>១៥.៣៤ | ០៩.៣៤<br>១៥.៣៦ |

SC

| | | | |
|---|---|---|---|
| | | ១៥.៤៧ | ១៥.៥០ |
| ការតាំងសំណួរទៅកាន់សាក្សី ឯម ភឿង (2-TCW-954) | សហព្រះរាជអាជ្ញា<br>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.៣៥<br>១៣.២៣<br>១៣.៥១<br>១៤.២៤ | ១១.៣០<br>១៣.៥០<br>១៤.២៤<br>១៥.២៥ |
| ការតាំងសំណួរទៅកាន់សាក្សី ភ្លៅ យ៉ាវ (2-TCW-934) | អង្គជំនុំជម្រះ | ១៥.៥២ | ១៥.៥៩ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជី រាយការណ៍ថាគ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ**

ប្រធានអង្គជំនុំជម្រះជូនដំណឹងដល់ភាគីអំពីសំណើរបស់ ជនជាប់ចោទ នួន ជា ដែលស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ និងសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើ អនុលោមតាមវិធាន ៨១.៥ ។

**ការកត់សម្គាល់លើការដាក់បន្ថែមនូវកំណត់ហេតុស្តាប់ចម្លើយពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២**

មេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានលើកឡើងពីការព្រួយបារម្ភរបស់ខ្លួនអំពីការកើនឡើង និងការបន្តដាក់បង្ហាញឯកសារស្តាប់ចម្លើយពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២។ សហព្រះរាជអាជ្ញាបានបង្ហាញប្រាប់អង្គជំនុំជម្រះថា ខ្លួននឹងជូនដំណឹងមកអង្គជំនុំជម្រះឲ្យលឿនតាមដែលអាចធ្វើបាន អំពីចំនួនសរុបនៃកំណត់ហេតុស្តាប់ចម្លើយដែលខ្លួននឹងស្នើសុំដាក់បង្ហាញ។ នៅក្នុងសវនាការពេលរសៀល មេធាវីការពារក្តី នួន ជា បានធ្វើការកត់សម្គាល់បន្ថែមអំពីចំនួនដ៏ច្រើននៃកំណត់ហេតុនៃការស្តាប់ចម្លើយពីសំណុំរឿង ០០៤ ដែលដាក់បង្ហាញនៅក្នុងសំណុំរឿង ០០២/០២។ ដោយហេតុនេះ មេធាវីការពារក្តី នួន ជា បានស្នើសុំផ្អាកសវនាការដើម្បីពិនិត្យទៅលើកំណត់ហេតុស្តាប់ចម្លើយទាំងនោះ។ មេធាវីការពារក្តី ខៀវ សំផន បានគាំទ្រទៅលើសំណើរបស់មេធាវីការពារក្តី នួន ជា ដោយកត់សម្គាល់បន្ថែមអំពីភាពច្រំដែលនៃកំណត់ហេតុស្តាប់ចម្លើយមួយចំនួន។ សហព្រះរាជអាជ្ញា

SC

និងមេធាវីនាំមុខ បដិសេធទៅនឹងសំណើរបស់មេធាវីការពារក្តី។ អង្គជំនុំជម្រះប្រកាសថា នឹងពិចារណាទៅលើបញ្ហានេះនៅពេលសមស្រប។

**<u>ការតាំងសំណួរទៅសាក្សី ឯម ភឿង (2-TCW-954)</u>**

សហព្រះរាជអាជ្ញាចាប់ផ្តើមធ្វើការតាំងសំណួរទៅសាក្សី ឯម ភឿង។ បន្ទាប់មក មេធាវីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន ធ្វើការតាំងសំណួរជាបន្តបន្ទាប់។ ការស្តាប់សក្ខីកម្មសាក្សីរូបនេះ ត្រូវបានបញ្ចប់។

**<u>ការតាំងសំណួរទៅសាក្សី ភ្លៅ យ៉ាវ (2-TCW-)</u>**

អង្គជំនុំជម្រះធ្វើការតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី ភ្លៅ យ៉ាវ (2-TCW-)។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយ ហើយគាត់មិនមានចំណងញាតិលោហិតជាមួយភាគីនៅក្នុងរឿងក្តី នេះទេ។ អង្គជំនុំជម្រះក៏បានណែនាំអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| លេខ E3 | លេខ កសចស | ERN (KH, ENG, FR) | ចំណងជើងឯកសារ | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|---|
| E3/5133 | | 00165258-00165264<br>00223197-00223202<br>00702332-00702338 | Written Record of Interview of ÊM Phoeung | P | 00165258<br>00165259<br>00165260<br>00165261<br>00165262 | 00223197<br>00223199<br>00223200<br>00223201 | 00702332<br>00702334<br>00702335<br>00702336 |
| E319.1.33 | | 00968170-00968196<br>00980277-00980305<br>00982607-00982632 | Written Record of Interview of (REDACTED) | C | 00968187<br>00968188 | 00980295<br>00980296 | 00982623<br>00982624 |
| E3/5831 | IS 19.42 | 00088472-00088479<br>00350097-00350103<br>00655657-00655663 | DC-Cam: Interview with Em Phoeung | P | 00088474 | 00350101 | 00655661 |
| E3/2818 | | N/A<br>00703863- | Book by HARRIS Ian, entitled: "Buddhism Under | P | N/A | 00704135 | N/A |

SC

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00704167<br>N/A | Pol Pot" | | | | |
| E3/259 | | 00089841-00089852<br>00184833-00184839<br>N/A | DK Government Legal Documents entitled "Constitution of Democratic Kampuchea" | P | 00089850<br>00089851 | 00184838 | N/A |

<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ហើយបង្គាប់អ្នកជំនាញតំឡើងឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោម។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ។

<u>កាលវេលាសវនាការបន្ត</u>

សវនាការនឹងបន្តទៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោង ៩.០០ ព្រឹក។

SC

ភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

ក្រឡាបញ្ជី | ក្រឡាបញ្ជី

R Crofl for

ជា ស៊ីវ... | Matteo CRIPPA